LIBRARY
BUDDHIST INSTITUTE

# សុភាសិតច្បាប់ស្រី

ពាក្យកាព្យ

អ្នកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ
តែង

បោះពុម្ពលើកទី ៣

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព. ស. ២៥០២

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្ស្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

៣១៤.៩១

# សុភាសិតច្បាប់ស្រី

ពាក្យកាព្យ

អ្នកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ
តែង

បោះពុម្ពលើកទី ៣

INSTITUT BOUDDHIQUE

BUDDHIST INSTITUTE LIBRARY
៤៩៥២ / ២០០០

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស. ២៥១២

# សុភាសិតច្បាប់ស្រី

ព. ស. ២៥០២

គ. ស. ១៩៥៩

3ុ០០

# BONS CONSEILS

( POUR LES FEMMES )

**( Poèsie )**

PAR

**OKNHA SUTTANTAPRIJA « IND »**

Troixième Edition

PHNOM - PENH

EDITIONS DE L'INSTITUT BOUDDHIQUE

1959

# អាធិធ័យ

សៀវភៅ “សុភាសិតច្បាប់ស្រី” នេះ ជាស្នាដៃរបស់លោកឧកញ៉ា សុត្តន្តប្រីជា ឥន្ទ ដែលជាអ្នកមានកិត្តិសព្ទក្នុងសតវត្សរ៍ទី ២០ ថាជាចិន្តកវីឯក ជាអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរ ជាអ្នកជំនាញប៉ុនប្រសប់តែងកាព្យឃ្លោងដ៏ពីរោះជាប់ចិត្ត ទាំងជាអ្នកមានព្យាយាមមុតមាំក្នុងការតែងកាព្យនិងតែងរឿងរ៉ាវផ្សេងៗ ទុកជាច្រើន ។

សុភាសិតច្បាប់ស្រីនេះ លោកតែងក្នុងកាលបានឋានន្តរ-ស័ក្តិ ជាកវី “ហ្លួងវិចិត្រវោហារ”; ពុទ្ធសាសនបណ្ឌិត្យបានចុះផ្សាយក្នុងកម្ពុជសុរិយាឆ្នាំទី ៦ លេខ ៤ ខែ មេសា ឆ្នាំ ១៩៣៤ ម្តងរួចមកហើយ ។ តែការផ្សាយនោះមិនសូវមានប្រយោជន៍ដល់ខេមរជាតិយើងប៉ុន្មាន ព្រោះហេតុបោះពុម្ពលាយចូលក្នុងរឿងផ្សេង ៗ ។ ឥឡូវនេះយើងបោះពុម្ពជាសៀវភៅ ១ ដាច់តែឯងវិញ ដើម្បីជា

ប្រយោជន៍ដល់អ្នកត្រូវការ ចំពោះតែច្បាប់នេះមួយមុខប៉ុណ្ណោះ ។

ឯបុព្វហេតុដែលនាំឲ្យយើងរើសយកច្បាប់នេះ មកបោះពុម្ពផ្សាយជាថ្មីទៀត ដោយ

១ – យើងប្រាថ្នានឹងផ្សាយការស្នាដៃនៃបិទ្តកវីឯកនេះ ជូនដល់បងប្អូនរួមជាតិទុកជាសម្បត្តិរក្សាខ្លួន តាំងជាកិច្ចរក្សាកេរ្តិ៍លោកទុក កុំឲ្យវិនាស ។

២ – យើងយល់ថាសុភាសិតនេះ ជាពាក្យដ៏វិចិត្រល្អិតល្អណាស់ គួរឲ្យបានទុកជាគំរូ ជាបែបបទច្បាប់តែងពាក្យបានខ្លះ ។

៣ – យើងយល់ថាសុភាសិតនេះ មានសារប្រយោជន៍ក្រៃលែង ចំពោះនារីដែលបានប្រតិបត្តិតាម សូម្បីតែបុរសក៏ប្រយោជន៍មានដល់ខ្លះ ។

៤– យើងយល់ថាសៀវភៅនេះ ទុកជាអាហារនៃចិត្តមួយមុខ ដ៏ចំឡែកប្លែកត្រកាល មានអានុភាពអាចឲ្យអ្នកអានបានស្វាងអធិដ្ឋារម្មណ៍បានខ្លះ ។

ក្នុងទីបំផុតនេះ ពុទ្ធសាសនបណ្ឌិត្យ សូមឧទ្ទិសបុញ្ញកុសលដែលកើតអំពីការចាត់ការបោះពុម្ពសៀវភៅនេះជូនចំពោះលោកអ្នកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ, សូមឲ្យលោកបានសម្រេចឥដ្ឋមនុញ្ញផល កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃទី ២៦ ខែមករា ឆ្នាំខាលទោស័ក ព.ស. ២៤៩៣

(គ. ស. ១៩៥១) ។

ពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ

## សុភាសិតច្បាប់ស្រី

ដុលីហត្ថ(១) នមស្ការដាក់លើកេស
តាងប្រទីបកោសុមប្រទុមទេស (២)
ចិត្តវិសេសសក្កត្រ័ធាទព្រះសាស្ដា ។
សឹងជាមោលីលោកតាំងត្រៃបក្រ
ជួបគល់ហាក់ប្រទីបស្វាងទូទិសា
កទូងបាត់ស្វាត់ទៅកុងអនា
កាន់មហានិញ្ញានបានសម្រាន្តរម្យ ។
មួយជនកជនទីបកើតកេស
តាំងចិត្តទេពសព្វវិសេសស្ថានសួគ៌សម
សូមចំរើនវុឌ្ឍិសិរីរម្យ
បួរជួយឃុំកំចាត់កាត់អន្តរាយ ។

១ ដុលី «ប្រពុំម្រាម» ហត្ថ «តដៃ» ។ ដុលី គឺអញ្ជលីៗក្លាយមកពីអញ្ជលី។
២ កោសុមប្រទុម = ផ្កាឈូក ។ ទេស = គ្រឿងទេស. គ្រឿងក្រអូប ។

ខ្ញុំបាទហ្វង់វិចិត្រពេកហារថែង
ប្រែសុន្ទរពាក្យតែងកាព្យក៏ប្រាយ
ទុកទូន្មានសត្រីស្រីទាំងឡាយ
តាមបរិយាយតម្រាប់ច្បាប់នារី ។
កំពុងពេញពាលរូបតរុណរ័ក(១)
បំរើនស័ក្តិគបល័ក្ខណ៍ជាសត្រី
គួរប្រព្រឹត្តតាមយ៉ាងព្រហ្មចារី
រក្សាកាយកុំបីឲ្យហ្មងសៅ ។
សេចក្តីជួ(២) គួរជំរុះពីរូបចេញ
សេចក្តីល្អគួរបំពេញឲ្យមាននៅ
តាំងចរិតប្រព្រឹត្តឲ្យត្រង់ត្រូវ
នឹងតវង្សពង្សផៅជាមង្គល ។

---

១ តរុណ = ក្មេង. កំឡោះក្រមុំ ។ រ័ក – ស្រឡាញ់ (ពាក្យថៃ) ។
២ ជួ = អាក្រក់ (ពាក្យថៃ) ។

សត្រីណា កើតក្នុងព្រះវង្សខ្ពស់
បំរុងយសថ្កុមកាយ ហ្លាយ[១]យកផល
គោងស្លួនចិត្តកុំបើកទៅតាមកល
ទើបមិនពាល់ពាក្យតិះអ្នកដទៃ ។
ខ្លួនករុណាពេញចំទង់វង្សនារី
ដូចមណីសូរ្យកាន្តមានដម្លៃ
មែនបើបែកប្រែកប្រេះកាលណានៃ
ក៏ថយថ្លៃចុះថោករកលក់ក្រ ។
ឯក្លួពាបកុំទៅប្រឹងឲ្យខ្ពស់ព្រាណ
មើលសន្តានតាមសណ្តាប់អ្នកល្អ
ទឹងស្លៀកពាក់សំពត់អាវព័ណ៌ខ្មៅស
តែងកាយក៏មើលកាយឲ្យហ្មត់ហ្មង ។
ការតែងត្លួសុភាពរៀបគាប់គល

១ ហ្លាយ = បំណង, ប៉ងប្រាថ្នា, សំគាល់ (ពាក្យថៃ)

នរណាយល់គន់សរសើរថាខ្លួនល្អង
បេះតែនប្រាណត្រូវប្រមាណមិនមានខ្គង់
ឋុះទំនងមយុររម្យ(១)សមសណ្ឋាន ។
មែនរូបល្អសសមឧត្ដមស័ក្ដិ
តែមិនបេះទុកដាក់ឲ្យសមប្រាណ
គន់មិនស្អុះកាយស្អើតឆើតទៅបាន
ខុសសណ្ឋានឥន្ទ្រីយ៍ឆវីវណ្ណ ។
ប្រការមួយទោះដើរដំណើរនាដ(២)
សន្សឹមយាសយាន៍បាទបរដោយជាន់
កុំបន់ឆ្វាយផ្ការហ័ត្ថក្រពាត់ព័ទ្ធ
កុំបើកជន(៣)បន្ទយថ្នក់ក្រោមផ្ដិត ។

---

យុរ = ក្ងោក, រម្យ = គួរពីករាយ ។ ២ ដំណើររាំ, ដំណើរ ។ ៣ ជន មើលថា ជន់ប្រែថា ដោះ ។

កុំដើរក្រោយកាយ យោគរោកខ្ទិកខ្ទក់
កុំសិតសក់កណ្ដាលផ្លូវមិនស្ទួ
ឃើញភ្ញៀវមកកុំលលេងតាមចិត្ត
មកស្ថានស្និតសឹមគិតប្រឹក្សាគ្នា ។
ឲ្យកំណត់កត់ចាំពាក្យណាគាប់
កុំបីប្រាប់ពាក្យពុតពោរពោណា
កុំនិយាយម្ហោះម្ហេះគេរកៀវគ្នា
កុំនាំពាក្យក្រៅក្នុងចេញចូលស្ថាន ។
ទីភូមិណាស្រីដួមិនគួរបេរ
ទៅអមអពេប់រក៏ជាសន្ដាន
ទីភូមិណាប្រុសដុំកុំលលាន
ផ្ទះមានគេបាស់គេដូនទៅ ។
ចូររាំងការណ៍គេក្ដុំបេរបេរ
តាមផ្ទះពួកនិករសោចញាតិផៅ

កុំទៀងផ្ទះញាតិមិត្រឥតគេហៅ
តែត្រាប់ទៅញយ ៗ គន់ថយស័ក្តិ ៗ
ទឹងអង្គុយឲ្យស្រគត់ស្រគំកាយ
កាលនិយាយកុំណាយសើចលោក់
កើតជាស្ត្រីក្តីខ្មាសមានច្រើនថ្នាក់
បូរស្ងួនស័ក្តិគ្រាការណ៍ក្តីហ្មង ៗ
នយៈនេត្រកុំសង្កេតឲ្យកឹង[១]ណាស់
មើលតែច្បាស់យល់ដាក់ដាក់វិញហោង
បើភ្នែកទៅយល់អស់កំឡោះផង
កុំមៀងហ្មងផ្អងផ្អៀងសំឡឹងគន់ ៗ
ឯនេត្រានាំការគ្នាឲ្យមួហ្មង
ដូចទំនងណៃនាំឲ្យសម្ព័ន្ធ
ពិតមិនពិតគេគិតដិតចិត្តទៅលប់

---

១ កឹង គឺកើង; លើសប្រក្រតី ។

ពាលជនប្រមាថមារយាទបាន ។

តែបើស្ដីស្រើនឹងប្រុសតែងប្រតិព័ទ្ធ

មិនដែលណានឹងអត់ក្ដីមេស្ដាន

មែនបើស្ត្រី ៗ ទុកតែក្នុងប្រាណ

កុំស្ត្រីស្មានចេញក្រៅឲ្យគេយល់ ។

ដូចសាខាព្រឹក្សាត្រូវខ្យល់បោក

រំជួយយោគក៏តែមែកមិនដេកគល់

បូរតាំងចិត្តសិណ្ឋិតកុំគិតខ្វល់

ទំនងគល់តាមរីរក្សាកាយ ។

ខ្លួនខ្លួននាងដូចយ៉ាងផ្កាប្រទុម

ទើបក្រពុំផុសជ្រែកវែកជលសាយ

ទ្រង់សុគន្ធកេសរក្លិនខ្ចរខ្ចាយ

មិនដែលណាយកមរគ្វី(១)លំអង ។

---

១ គ្វី ប្រែង ឈ្មី ទេពិរ ។

គ្រាន់បានក្រេបរសជាតិរេណុ (១) ផ្កា
ឆ្អែតកាលណាក៏លាណាកចេញផ្គង
មិននៅផ្គង់បំរុងរសទៀតលង
ដូចទំនងចិត្តប្រុសមិនខុសគ្នា ។
បើប្រុសណាប្រាថ្នាមករួមរ័ក
ឲ្យស្គាល់ជាក់ដើងប្រុសនោះយ៉ាងណា
វិស័យប្រុសច្រើនប្រាជ្ញប្រែសត្យា
ដែលជាស្រឡាញ់ចៅតើម្តេចមិញ ។
ចូរពិនិត្យគិតពឹងឲ្យដឹងណែ
កុំធ្វើតែចិត្តហ័សក្រែងផ្តាសវិញ
យោគទៅមុខមុកឲ្យបែងបទចេញ
ឃើញចំណេញពេញចិត្តសូមចេញមុខ ។
ត្របៀកត្ពុកុំលុះលលើតាម

១ រេណូ=លំអង ។

សង្កត់តាមសង្កិនស្ដាប់ស័ព្ទទំនុក
ល្មមនឹងគេបប្អូនឹងកែបំបែរមុខ
ប្អូជាល្មមរាក់ទុកក្ដូ(១)យ៉ាងណា ។
គោងគ្រឹកក្រង(២)ហ្មងមើលឲ្យប្រាកដ
កុំអាលជឿខ្យល់មាត់ប្រុសបរោ
ឧបាយប្រើមេអណ្ដើកមានប្រាជ្ញា
នាំសារពការប្រឡោមលោមបំព្រាង ។
មេអណ្ដើកកុំទៅជឿជាបន្ទាត់
អណ្ដាតបត់ថ្លូត(៣)ភរលច្រើនយ៉ាង
សរសើរតែពីមានបុណ្យក្ដូនខុនណាង
មកអួតអាងឲ្យតែលុះចុះចិន្ដា ។
តែគឺមោះមិនបំពោះដូចនិយាយ
នឹងបែរកាយបៀតកើយទៅត្រង់ណា

---

១ ធ្វើខ្លួន ។ ២ គិតពិនិត្យ ។ ៣ និយាយប្រមូលផ្សំពីនេះ

ដូចគេករប្រាប់លាភស្រុកលក្ក
មិនគួរយាត្រាតាមពាក្យគេប្រាប់ ៗ
ផ្លូវឆ្ងាយក្អែកប្រៀបដូចក្អែកងងឹត
ខឹងសង្កេតពិតមិនពិតតាមសូរស័ព្ទ
គេខឹងនាំទៅស្លាប់ក៏ស្លាប់ឆាប់
ខឹងជឿស្ដាប់មនុស្សនេះក៏ក្រសល់
មេអណ្ដើកដូចខ្មោចបិសាចខ្លួប
តែគេបន្តិចតូចក៏ក្លាយដល់
យកអាសាប្រាថ្នាស៊ីកំណប់
មិនដឹងកល់តែជឿក៏អស់ខ្លួន ៗ
ឯក្ដីជួតឯងក៏ដឹងគ្រប់
ការខឹងគប់សេពមិត្តគិតឲ្យល្អួន
ពិគ្រោះស្ដាប់អាការឲ្យម៉ាំមួន
កុំអាលព្រមយ៉មខ្លួនចុះឆាយ ៗ ៗ

មែនការកេស្វាមីនេះក្រណាស់

វាច្រើនផ្កាសតែកញ្ចាសុរាចាយ

បើស្រីណារួមត្រេកផ្ដេកផ្ដិតកាយ

គង់អន្តរាយអ័បចុន[1]ធនធានក្រោយ

ជម្ពាតិប្រុសខូចពូជពាលពិត

វាច្រើនតែប្រព្រឹត្តខុសទោសឲ្យ

សាហាវពើកិច្ចការមិនបង់គុយ

បានមួយរយបង់មួយពាន់មិនគ្រាន់ចាប

ពុំមានគិតជួញប្រែស្រែចំការ

បេះតែតែងអាត្មាដើរកែក្រាយ

នាំភៀនផូង[2]ចូលពេងសុរាចាយ

ផឹកអាភៀនញៀនកាយតាល់អស់ប្រា

កាលបើអស់ធនធានគ្មានអ្វីកែ

---

១ អ័បចុន=ទាល់ក្រខ្សត់ (ពាក្យថៃ) ។ ២ ផូង–ពួកបន

កំលើកយកភូមិស្រែទូវភូមិស្ថាន
ទៅបញ្ចាំឲ្យគេអន្តរធាន
ចិត្តមិនមានអាណិតកូនប្រពន្ធ ។
លុះអស់ខ្លួនកើតក្លាយគ្រាប់ប្រុប
ដើរលេងយប់គប់គៀនគិតលួចប្លន់
លុះកម្មផលអកុសលឲ្យគេពាន់
គេក៏ព័ន្ធចាប់ទៅជូននគរបាន[1] ។
ឲ្យចុះក្ដីវាយខ្នងចងហាលថ្ងៃ
កើតចង្រៃនៅគុកទុក្ខរំខាន
ខ្លួនប្រពន្ធឯណាក៏ធន់បាន
គង់ចុះសានក្រមច័ណ្ឌព័ន្ធកងង ។
បែបយ៉ាងនេះមានច្រើនហើយអនគ្គ[2]

នគរបាល អានឲ្យលឺថា នគរបាន ។ ២ អនគ្គ អានឲ្យលឺថា
ង ។

បូរខំប្រុងគំនិតគិតឲ្យវែង
កុំឃើញតែរូបល្អស្រឡាញ់ឯង
ដល់ក្រោយលិចគិតវែងឯណាបាន ។
ប្រុសខ្លះនោះតែងអស្ដដើរបង់ស្រី
បងការខ្ចីប្រាក់គេមកតែងប្រាណ
ឃើញគល្យាប្រាថ្នាកែរម្យស្ពាខ
ទើបអ្នតប្រាណថាខ្លួនអ្នកមានជំ ។
យកប្រាក់សូកមេអណ្ដើកអណ្ដាតជា
ឲ្យមកស្ដីពណ៌នារឿងមនោរម្យ
ឯងមិនដឹងក៏ស្មានថាមានជំ
ក៏ជឿចុះចិត្តពុំមានសង្កា ។
លុះដល់ថ្ងៃម្ចាស់ប្រាក់គេមកដល់
ទារប្ដឹងផ្ដល់ទាល់លុះចុះអាជ្ញា
ឯងប្រពន្ធក៏ព័ន្ធជាមួយគ្នា

ទឹងគេបពងណារួបកំនួបជាប់ ។

មានប្រុសខ្វះខ្ជីខ្ជាខ្ជិលរកស៊ី

បង់បានតែនារីគេមានស្រាប់

ស្អានតែអង្គឲ្យតែប្រពន្ធផ្គាប់

លុះអស់ទ្រព្យគេបត្រឡប់មិនពប់អាន ។

ប្រុសខ្វះនោះលុះល្បែងបៀរប៉ោជូ

ចិត្តមើមួយលួបលេងផឹកស្រាកស្រាន្ត

សំពត់អាវផ្តិលជាសត្វគោកពាន

យកទៅទុយ(១)តាមពានពេងបំណាំ ។

តែកង់ចារុំសេមាដែលកូនពាក់

លួចស្រាយដាក់ហោប៉ៅទៅបញ្ចាំ

កូនប្រពន្ធក៏ផងទៅតាមកម្ម

មុខក្រជាំទ្រាំបំរើការគេទៅ

---

១ ទុយ ចប់តែ «ទុកទ» ទេដឹង ?

ហៃអនង្គនារីរូបចំណាប់

អញ្ជើញស្តាប់បរិយាយយើងប្រដៅ

ប្រុសឥឡូវច្រើនជួជាតិណាំហៅ

កុំបើកទៅរួមរកឲ្យធ្លាក់ព្រាណ ៗ

វិស័យប្រុសខុប្រិតចិត្តអកុលេង

នាំឲ្យវង្វេងវរខាន

ពោះមានព្រាក់ពាក់ករជាកោដិលាន

គង់អន្តរធានគ្មានសល់ផលកូនទៅ ៗ

មានប្តីខ្វះស្តុះគំនិតចិត្តស្មើរបែក

អន្ទុយជួតតែទឹកក្អែកអន់ក្លួលក្តៅ

ស៊ូទ្រទ្រាំតាមកម្មតាំចិត្តទៅ

ទឹងវែបរទៅតែខ្លួនក៏ជួនបាស់ ៗ

តែចិត្តមនុស្សនេះមាននះទៅរកខុស

ម្តេចមិនមើលតាបខ្ពស់ឲ្យជាក់ច្បាស់

ឃើញតែប្រុសកំព្រើលទៅផ្ដេសផ្ដាស
ផល់ក្រក្រោយគិតក្រឡាស់សែនក្រក្រី ។
ជាស្រីល្អគាលពេញក្រមុំ
បំរើនសមស័ក្តិយសព្រោះស្វាមី
តែចាស់ចុះគិតលៃងស្វែងរកថ្មី
កំសាបសូន្យរាសីដូចត្បូងផា ។
ល្អអាក្រក់កំតែគ្រានៅក្មេងគ្រាន់
ចុះមានប្ដីពីរបីជាន់កំអន់ថ្វា
នឹងត្រឡប់ក្មេងវិញបានកាល ណា
ផុតប្រាជ្ញាទាំងគិតតែមានតែទុក្ខ ។
បើស្រីណាកបក្តើតរិយា គាប់
ទោះខាតទ្រព្យខានផនចុនសព្វមុខ
គង់មានគេសង្គ្រោះជួយដោះទុក្ខ
បំរើនសុខរាសីសួស្ដីផា ។

ប្រៀបដូចមាសនព្វគុណគប់ស្មើ
មានដំឡៃឥតបីនឹងពណ៌នា
ជាបើត្លួចិត្តឥតតំរៀយ
នឹងដុសខាត់យ៉ាងណាមិនថ្លាបាន ។
ប្រៀបដូចមាសក្រឡៃស្មើអាប់
នឹងប្រដាប់កាយក៏មិនថ្កើងថ្កាន
អ្នកត្រូវការតែងអង្គមិនចង់បាន
លក់ដូរគ្មានដំឡៃថ្លៃថយថោក ។
ហេតុនេះនួនប្អូនស្ងួនក្រាបប្រាណ
កុំឲ្យមានមន្ទិលមួហ្មងមក
គួរមិនគួរគួរគិតឲ្យត្រូវប្រែក
កុំកាន់យកជាគាប់ប្រែកបកាយ ។
ប្អូនទៅក្មងខ្វល់ញាតិវង្ស
ក្រាបចូលតាមវង្សសែស្រឡាយ

គួរកើសេកឯកឈ្មោះត្មុសុសសាយ
កុំស្មុះទៅតាមព្រះពាយតំពាក្យប្រុស ។
ឯខ្យល់មាត់បុរសនេះខ្លាំងក្លា
លោកតែងថាអណ្តាតនេះដ៏ងរស
បូររាំងកុំឡាំងខ្យល់បុរស
កុំឲ្យចូលជ្រាបអស់សពាង្គកាយ ។
បើគេស្ម័គ្រឲ្យស្តូមដល់ម៉ែឪ
កុំរត់ទៅដោយគាមតាមអ៊ាយ ។
ដល់គេស្អប់ឯងត្រឡប់ជាមេម៉ាយ
ឯកាកាយខ្មាសគេក៏ខេពកពន់
ខាងម៉ែឪក៏ក្រោធពិរោធខ្លាំង
បង់រាយដេរដោយកុំឡាំងទោសោលន់
ព្រោះគាប់មុខលោកខ្មាស់អស់មហាជន
មិនគិតគន់ស្រឡាញ់ប៉ុណណាទើបបានទុក្ខ ។

បើប្រទះម៉ែឪចិត្តខ្ញាំនៃក្រ

ក៏លក់ថ្លៃឲ្យទៅប្តីបរាមុខ

បើប្រុសក្រកុំគេឡើយក្តីសុខ

ខ្ជនធ្វើល្មក់(១)គោរងលក់ខ្ជននាងឯង ។

ឱនបន្ទោសម៉ែឪឯណាបាន

ព្រោះសន្តានគិតខុសលុះដោយល្បែង

ស្រឡាញ់ប្រុសចុះពាលម៉ែឪឯង

មិនគិតក្រែងគុណលោកប៉ុនទាំងភ្នំ ។

លោកចិញ្ចឹមមកប៉ននឹងឲ្យមាន

គូបូពណ៌វណ៌នឹងស៊ុំ

លុះកូនស្រីទូរយសខុសអារម្មណ៍

ទើបក្រៀមក្រំក្រោយកូនសូន្យគំនិត ។

---

១ ល្មក់ ក្លាយមកពី លាមក ។

បើកូនជាក៏មានមុខសង៉ា(១)
ញាតិវង្សពង្សក៏ថ្វាចិត្ត
ពោះព្រៀងលាននៅនាស្ថានឆ្ងាយជិត
ក៏មានចិត្តសរសើរខ្លួនអនន្ត ។

ហៃនារីពោមយង់ចូរប្រុងប្រាណ
កុំលានតាមចិត្តដែលគិតបង់
គិតទុកមុខម្ដាយឪពុកត្រកូលវង្ស
រក្សាអគ្គិឲ្យគង់ក្ដៅថែម ។
កាលមុំជោរគួរជុំរុះជ្រុះចាកចេញ
កុំជ្រុះឆ្ងាយឲ្យរលេងពីដើមទៅ
កុំដណ្ដើមជ្រុះមុនឲ្យហួនសោ
យល់មិនត្រូវច្បាប់នារីពីបូរាណ ។
កុំគិតឡើយត្រង់គួតង់បានទេ

១ សង៉ា=ល្អរុងរឿង គួរឲ្យសង្ហា (ពាក្យថៃ) ។

ខុសព្រាហ៍តែធ្វើការរកធនធាន
សន្សំទ្រព្យសម្បត្តិឲ្យកើតមាន
ទើបនឹងបានពឹងពំនាក់នៃអាត្មា ។
ទៅខ្សត់ក្តីបើល្អនឹងតវង្ស
គង់អ្នកល្អស្មើពង្សមកប្រាថ្នា
ម៉ែឪរៀបទុកដាក់តាមធម្មតា
មានសង្ហាកសីល្បិ៍ក្តីឈ្មោះ ។
មួយការស្រីគប្បីរៀនឲ្យចេះ
ជាបំណោះគ្រឿងរកចិញ្ចឹមពោះ
ញាតិសន្តានឆ្ងាយជិតតាំងចិត្តស្មោះ
កុំកឈ្មោះឲ្យមោះជាសត្រូវ ។
អធ្យាស្រ័យអ្នកក្រៅហៅថាញាតិ
ពឹងផ្ញើមាត្រៃក្រងមានធុរៈក្តៅ
ខ្ញុំកំដរយកស្តូលប្រើហៅ

ទឹងផេរទៅហៅមកយកតែការ ៗ
រឿងចំរាបបន្អែបសែមសមហាត់
ឲ្យបេះបាត់តាមរឿងគ្រឿងអាហារ
ចូលជំនុំមានរាល់មង្គលការ
កាន់ភ្នាក់ងារស្មើៗ គប្បីផ្គង់ ៗ
ចុះជំនុំឲ្យប្រចាំគេអ្នកល្អ
បៀម (១) ខ្លួនក្រុំកុំដំឡើងតំកើងអង្គ
គេឲ្យអ្វីប្រមាណយកឲ្យសមគ្រាន់
កុំលោភលន់ចង់លាភភាពទឹងអាប់ ៗ
ចូល (២) ធ្វើអ្វីគប្បីដណ្ដឹងសួរ
ការមិនគួរខ្លួនក្រុំកុំអាលបាប
គេបង្គាប់សូមធ្វើតាមបង្គាប់
បាប់ឲ្យជាប់តាមការអាសាគេ

---

១ បៀម– ប្រុង ( ពាក្យថៃ ) ។ ២ ចង់ បានសេចក្ដីល្អជាង ចូល ។

បើចូលជាសរួមមួយនឹងអ្នកល្អ
លូកសម្អន្ទក់នៅមុខមេ
កុំលលាមលោលូកទៅមុខគេ
ប្រមាណតែល្មមស្រួលខ្លួនពាន ។
អ្វីឆ្ងាញ់នៅឆ្ងាយកាយមិនដល់
កុំវល់លូកឲ្យគេជាបាន
ឆ្ងាញ់មិនឆ្ងាញ់នៅមុខខ្លួនប៉ុន្មាន
ខ្លួនពានគ្មាននិន្ទាជាសួស្ដី ។
ជានារីគោនរៀនកិច្ចដាក់ទុក
ការស៊ុបុកដេកដើរធ្វើអ្វី ។
មើលប្រមាណតាមស្ថានខ្លួនជាស្រី
ជាតិសត្រីស្រីក្រមុំធំឥរិយា ។
មែនបើធ្វើការអ្វីឲ្យស្រេច
កុំភ្ញាំងភ្លេចគេចោលទៅឯណា

រាំងវែតកិច្ចការនៃអាត្មា
កុំខ្ជីខ្ជាគប់កៀនលៀនពៀនទៅ ។
បើនឿយណាស់ប្រះវេកទៅជាវិញ
កុំបូលបេញឥតការយល់មិនត្រូវ
អ្វីឆោឡោកើតឡើងកុំផ្អើលទៅ
ស្ដាប់ឲ្យជាក់ពក់ជ្រៅសូមសួរគ្នា ។
រាំងមើលទីស្ថានរបស់ទ្រព្យ
គន់ឲ្យសព្វខេះនោះនៅត្រង់ណា
ឃើញខាតបុះគួរឲ្យបំពេញពា៉
របស់ណាគួរបំណាយឲ្យចាយបេញ ។
មានមួយស៊ីងប្រឹងប្រុបឲ្យគ្រប់បាទ
កុំឲ្យខាតដោយការមិនគួរទិញ
បើស៊ីតិចធ្វើតិចគិតឲ្យពេញ
កុំចាយបេញលើសកំណត់ខ្សត់ទឹងផល ។

មិនគួរទិញកុំទៅទិញបុលគេមក

មើលលៃលកល្មមតែមួយគ្រាល្វល់(១)

បើម៉ែឪចាស់ជរាពេគាដល់

ខំខ្វាយខ្វល់ប្រតិបត្តិលោកទាំងទ្វី ។

ព្រោះជនកជននីទីពប់អាន

បង្កើតប្រាណបានធំដឹងសេចក្ដី

ថ្នមបបក់បញ្ចុកបាយចំណី

ប៉ីងនឹងពឹងកូនស្រីជាត្រីមុខ ។

បើនួនជាមានចិត្តឧបត្ថម្ភ

កុសលនាំជួយឲ្យបានក្ដីសុខ

នឹងប្រាកដកេរ្តិ៍ឈ្មោះឮសុសស្រុក

ជពបលុះផ្តោះមុខកាន់ពិមាន ។

ទេពតាសាឲ្យសទាំងអស់នឹងសាទរ

---

១ វល់ ផ្លាស់ វ ជា ល រួចផ្សំនឹង វ ជា ល្វ ។

ចំរើនពរបរិបូណ៌សុខក្សេមក្សាន្ត

ប្រកបយសខ្ពស់ល្អតវៀ៉ន(១)

ព្រោះដែលបានប្រតិបត្តិម៉ែឪល្អ ៗ

មែនស្រីណាប្រុសព្រើទុច្ចរិត

ពុំមានគិតគុណលោកចិញ្ចឹមបបក់

ឃើញម៉ែឪដល់នូវសេចក្តីក្រ

មិនតបតគុណលោកប៉ុនគេសី ៗ

គិតខ្មាសគេក្រែងមានគេសួរថា

នេះមាតាបិតាខ្លួនប្ញើ ?

កែបន្ទប់លុបគុណបុព្វការី

បដិសេធបិទសេចក្តីដេវទផ្តាស ៗ

យកផុតពុកម្តាយខ្លួនជាទីងង៍

ស្តីគំហកស្តីកំហែងមិនក្រែងបាស់

១ រ៉ាន ប្រែថា «ព្វូន» (ពាក្យថៃ) ។

ប្រើកែខ្លួនតាមក្រោយមិនមានខ្ចោស
តាំងប្រើប្រាសសព្វទិនមិនប្តូរ ។
ស្រីយ៉ាងនេះតែរលត់ផុតជីវី
គង់មិនរួចឡើយក៏ធ្លាក់តិរិយា
មិនឃើញសែងសុរិយ័នព្រះចន្ទ្រា
នៅសោយទុក្ខវេទនាក្នុងអវិចិ ។
បើរស់នៅជាមនុស្សយើងនេះណា
ហ៊ុងទេព្តាចង់ផ្តាសាប្រក្រតី
ឲ្យគោកយ៉ាកលំបាកកើតអប្រិយ
លើសលែងក្តីដែលធ្វើឲ្យលោកក្តៅ ។
ទោះជាមានធនធានទ្រព្យទាំងឡាយ
គង់អន្តរាយខ្ចាយពាសវិនាសទៅ
កើតចោរភ័យអគ្គិភ័យមកសត្រូវ
ព្រោះចិត្តខ្មៅទុច្ចរិតគិតនេរគុណ ។

ស្រីយ៉ាងនេះប្រុសកុំនៅបែបរួបរ័ក
នឹងជយស័ក្ដិយសសោបលាភខាតទុន
ត្រឹមតែម៉ែឪវាគ្មានការុណ្យ
នេរគុណមិនមានគិតអធិប្បា. ៗ
ស្រីមិនល្អគួរកុំគប់សម្គពជិត
យកជាមិត្រឲ្យហ្មងដល់អាត្មា
គួរចៀសវាងឲ្យឆ្ងាយចេញពីវា
ស្វែងរកគ្នាចិត្តបុណ្យដឹងគុណគាប់ ៗ
ប្ដូរទូន្មានចិត្តខ្លួនឲ្យស្លូតត្រង់
រក្សាវង្សជាក្រមុំតាមក្រមច្បាប់
កុំមួរម៉ៅទៅដោយការសាប់ឡប់
មើលសណ្ដាប់អ្នកល្អតវង្សវ៉ាន ៗ
កុំធ្វើក្រៅច្បាប់ស្រីឲ្យក្ដិខុស
ស្រឡាញ់ប្រុសក្រៅចិត្តម៉ែឪប្រាណ

កាត់ប្រយោជន៍សារលោហិតមិត្រសន្តាន
ឲ្យលោកបានទុក្ខទោសកង្វល់លោកិយ
ប្រុសដួជាតិញាតិស្អប់បំបែកចេញ
ទៅស្រឡាញ់តែតាមយកជាប្ដី
ជំរត់គ្នាទៅឡើងលោកមន្ត្រី
តជាក្ដីទឹងម៉ែឪនៃប្រាណ ។
ម៉ែឪសោកក្រោធសល់ទាល់គំនិត
មិនដឹងគិតកែការក្ដីនោះបាន
នាំគ្នាយំក្រំចិត្តអាណិតប្រាណ
ព្រោះកូនគ្មានរៀនខ្នាសផ្ដាសខុសផ្លូវ ។
លេបក៏ស្លាក់ខ្ជាក់ក៏ស្លូនលែងមិនបាន
ទឹងគិតអាងការរៀនគ្មានផ្លូវទៅ
ខ្លះមិនដឹងគេក៏សួរដល់ម៉ែឪ
ថានាងនោះកូនចៅអ្នកណាហ្ន៎ ។

ខ្លះដែលស្គាល់គេក៏ប្រាប់គ្នាសាយសុស

ថាមារនោះកូនអ្នកនោះឮគេថា

រត់តាមប្រុសឈ្មោះម្លោះឡុះសតឆ្កួត

អនិច្ចាប៉ៃផុះទៅមិនសុខ ។

ខ្មាសអើយសែនខ្មាសគេពេកក្រៃ

កូនចៅស្រីអប្បលក្ខណ៍បំបាក់មុខ

មិនអាណិតចិត្តអ្នកម្ដាយឪពុក

បំណាច់ថ្នមតាំងទុកតាំងពីគេពា ។

នៃអនុត្តរារូបប្រសើរ

នាងកុំដើរផ្លូវខុស ណា ធ្ងន់ណា

ចូរតាំងចិត្តស្រណុកនៅជាយហោ

ការកេរ្តិ៍វង្សត្រកូលបាទគន្ធរ ។

កើតជាស្រីគ្មានអ្វីសងគុណប៉ៃ

វេក្កតៃតេក្ដ៏លោកឲ្យថាវេរ(១)
ស្មើសធ៌គុណដែលលោកពុទេវ
ប្រាកដត្ថនាមកខ្ចេរខ្ចាយទៅ ។
ប្អូនស្ងួនចិត្តគិតកាយជាគ្រុំ
កុំនិយមឲ្យរុសពីប៉ែផ
ស្ងួនភក្ត្រចរិតឲ្យត្រឹមត្រូវ
ដឹកលំនៅកន៍ពាក្យគុណទាន ។
ទោះប្រស្រ័យបរបានណានោះ
កុំពោលពាក្យទ្រគោះឲ្យមោះមាន
ចិនត្តស្ត្រីញញឹមឲ្យខឹនខាន
ពាក្យតិរច្ឆានកុំថ្លែងសំដែងចេញ ។
ប្អូនដើររៀនផ្លូវឈ្មួញលក់ដូរ
ស្ដីឲ្យគួរពោលពាក្យជាសម្លាញ់

១ បាវរ «ហ៍ប្អូន» ពាក្យបាលី , សំស្ក្រឹតក្លាយជា «ស្គួពរ»

ទើបលក់ដូរទិញស៊ាយបានចំណេញ
ព្រោះគេពេញចិត្តចាប់ដោយពិតា ។
ដោយមនុស្សនេះនឹងសំគាល់ត្រឹមខ្យល់មាត់
ការមានខ្សត់កើតយសព្រោះដំហ
បើពាក្យល្អពាក្យពីរោះពេញកាលណា
គេមេត្តារាប់អានបានណាភលន់ ។
ទោះប្រុសណាមកប៉ះបំណាន់ចន់
កុំពិរោធក្រោធបង្អើតកក់អន់
កាលមិនស្នេហ៍ក៏កុំតែតពាក្យព័ន្ធ
ពំនឹងបណ្ដោយផាន់ព្រោះធ្លាប់ស្និទ្ធ ។
ឯជាតិប្រុសទោះជាព្រើលមិនមើលបាន
បើព្រមលួមប្រាណទើបហ៊ានជិត
បើស្រីពំពារនឹងទឹងនៅទិត្យ
មិនហ៊ានជិតបួលស្នេហ៍ទេអន្ត ។

ទឹកទឹងហូរ ៗ តាមប្រឡាយជីក
ផ្កាទឹងរីក ៗ តាមសែងសុរិយង់
ព្រះពាយផាត់គន្ធភមរ(១) ត្រង់
ប្រុសអាចបង់ព្រោះស្រីបើកបើកអាការ ៗ
ហេតុនោះខ្លួនបួរស្ងួនក្រព្រាណ
កុំឲ្យមានហ្មងសៅផ្លូវទុច្ចារ
កាត់តម្រាយប្រឡាយប្រុសប្រើអាការ
កុំស្អិតស្អាលដោយសារការមិនត្រូវ ៗ
ពាក្យសំដីស្ដីតាមការណ៍ដែលមាន
និយាយបានមិនហាមទៅតាមឡៅ
ហាមតែកើតវិយាការមិនត្រូវ
បង្ហាញផ្លូវឲ្យប្រុសខុសវេណី ៗ
ច្បាប់លោកហាមគួរតាមច្បាប់លោកហាម

១ គន្ធ “ ក្លិន ” ភមរ « ឃ្មុំ »

កុំមួតាមកាមរាគពេលឥន្ទ្រិយ
គិតឲ្យត្រូវតម្រាប់ច្បាប់នារី
ប្រកបការរកស៊ីតាមធម្មតា ។
មួយការដេកដើរឈររន្ទុយក្តី
ចូររាំងកាយស្រីតាមតំរិយា
កុំបន្ទាន់រាន់ដើរក្តួតភ្លាត់ថា
មែនបើភ្លាត់បាតដួលខ្មាសគេ ។
ឃើញអ្នកចាស់ឬអ្នកដ៏ប្រជុំទាធ
កុំគ្រាក់សវៃការធិបំបែរ
ចូរទុនខ្លួនទៅសុំផ្លូវគេ
ឲ្យគេអត់ទោសបេសូបយាត្រា ។
    មួយបើទៅផ្ទះគេដោយមានកិច្ច
តែស្ទួរេច[១]ផ្ទះឆាប់មើញ

---

១ ស្ទួរេច គឺ ស្រេច, រួច, ចប់ ។

កុំទៅយូរក្រែងគេដិនកើតទន្ទា ៚
សេចក្ដីជ្រួបច័ក្សជាមានផលកាយ ។
បើអគ្គីយក្ខូររកាំងសំពត់ស្បៀក
ទឹងស្បៃកៀកពោមពុធសំយុងជាយ
មើលសម្រួលឲ្យស្រួលលំនាំកាយ
យោមសប្បាយទឹងសើច ៗ ឲ្យគួរ ។
ប្រើសទ្ទឹមញញឹមតែត្រឹមត័ក្រ
កុំសើចបើកស្បូរលាក់ឲ្យលាន់ស្បូរ
កុំក្តាផែក្តាដើងឡើងរប្បូរ
ពាក្យមិនគាប់ពេលមិនគួរឲ្យពុទ្ធាយ ។
ទឹងតែងឝ្គុក៏កុំស្លែកការតែង
ទឹងលាបម្រេងក៏កុំលាបឲ្យហួសខ្លាយ
ទឹងលាបម្សៅកុំពកបឲ្យពៀងកាយ
គេទឹងសើចឡកឡាយជល់ថោមផៅ ។

កាលយាមត្រជិសស្រាន្តមានការហ៊ុង
តែងឲ្យសមតាមក្រសួងតាមពង្សផៅ
លុះអស់ខែត្រទេសកាលធ្វើការទៅ
កុំមួនៅតែងតួអស់ខួបខែ ។
ខ្លួនអ្នកក្រត្រូវពិនិត្យគិតរកស៊ី
តាមវេណីត្រកូលវង្សដុម៉ែ
ដាំដំណាំដូងស្វាចំការស្រែ
ទស្សាហ៍ថែមើលស្មៅជ្រួយដាក់ដី ។
រៀនវិជ្ជាឲ្យចេះជាគ្រូគេ
ទើបចំនេរមិនសូរទៀយឥន្ទ្រិយ
ចេះស្ងើរ ៗ មិនស្ងាត់ហត់ពីបដី[១]
ជានារីមិនចេះរើប្តីឡើយឯង ។
មានខ្ញុំស្រីខ្ញុំប្រុសប្រើសប្បាយ

១ គិមធី "ពេញទី, ហ្វូសចិត្ត" ពាក្យថៃ ។

ខ្លួនជានាយល្ងង់ការពារមិនក្រែង
បេះជាជានមិនព្រមទៅរែកសែង
ការផងឯងត្រូវយកចិត្តទុកដាក់ ។
មានមាសប្រាក់ដាក់ទុកសម្រាប់កាយ
កុំបែកចាយឲ្យគេរួតថាមានប្រាក់
ការគួរចាយឲ្យចាយប៉ុនស័ក្តិ
សង៉ាក៏ត្រូវព្រោះប្រាក់តាំងជាមុខ ។
កុំកកាញ់កំណាញ់ក្រៀតក្រោ
កុំសទ្ធាធ្វើបុណ្យយល់ដោយមុខ
កុំអាងប្រាក់ចាក់ចាយរាយស៊ីគ្រលុក
ចាយមើលមុខទុកមើលក្រោយការគ្រាក្រ
ជាស្ត្រីភាក់ង៉ារបំណែកផ្ទះ
មើលជម្រះបោសប្រាសតាំងឲ្យល្អ
ទាំងផ្ទះបាយខុសទឹកស្រូវអង្ករ

គ្រឿងផាំស្ដែងថាំឲ្យហាំប្អូន ។
ក្លីកយើសទុកតាមកន្ដែង
ក្ដីបាត់ចិត្តស្ដែងគេឲ្យក្លួន
ដល់ត្រូវការបានស្រាប់សម្រាប់ខ្លួន
មិនលំបាកយ៉ាកខ្លួនណាក់ខ្លួនណា ។

ប្អូនះសោតយប់ទិត្រាវាលាដេក
ចូលដំណេកកុសត្រាសទំនិទ្រា
កុដទៀនធូបប្រណបង្គុំប៉ា
ក្រាបវន្ទាលើកគុណព្រះរតនត្រៃ ។
បីដងស្រេចសឡឹបនិទ្រាទៅ
ទើបកើតនៅវិបុលបក្តិលជ័យ
ពេលទឹងក្រោក ៗ បុនអរុណរៃ
កុំដេកហួសដល់ថ្ងៃត្រង់ខ្លួន ។
ក្រោកបេញបកយកទឹកទនលុបភក្ត្រ

សំអាងខ្លួនទួនអ្នកឲ្យសមសួន
ប្រកបការបណ្ដាកេនរបស់ខ្លួន
មើលថៃផ្ទូនក្នុងក្រៅតាមក្រិត្យស្រី
កុំប្រមាទសន្ធារអោត្មាក្មេង
ប្រកបលេងដោយល្បែងពុំដក្តី
អំពើពាលនាំទៅឲ្យអប្រិយ
ការលោភិយប្រៀនកំទាំវង្វេង ៗ
កុំគប់ស្រីសាមាន្យសន្ដានជួ
ដែលតែងត្អូញសបរិតចិត្តអ្នកលេង
តែសុរិយាទន់ ១ បេញទន្ទេង
តាំងសំដែងក្វែងឲ្យប្រុសយល់ខ្សែបខាយ
តែព្រឹកព្រានស្អាងស្អិតសិតសយសក់
ធ្វុះកញ្ចក់យេដងហ្វូងតែកាយ
គ្រង់កិច្ចការកេសុីកំទៀយណាយ

ដើរកែក្រាយគប់កៀនពាលដូចគ្នា ៗ
តែឮស័ព្ទស្នូរស្គរឮគង់ឃោះ
ក៏ក្រាប់ដើរស៊ើបស៊ុះសួរគេថា
ថ្ងៃនេះតើបានព្យានកំភូមិណា
លុះដឹងថាពីឯណោះស្ទុះលទៀត ៗ
ចូលជ្រកជ្រៀតបៀតប្រុសត្រដុសព្រាណ
ខឹងដូចបុងកម្ហជានគ្មានកំរើក
ប្រុសលលាមលូកផ្តិតដោយចិត្តបើក
លុះល្ងោនលើកពីពីនាំគ្នាទៅ ៗ
ពាល់ខុសខ្មោចគេរ៉ែអាសោចព្រួសស្រុក
ម្តាយឪពុកដាក់មុខទុក្ខផ្សាក្តៅ
កាប់ចាំងអង្គកាប់ចាំងវង្សព្រៀងព្រួដដៅ ៗ
ព្រោះមិនត្រូវច្បាប់បុរាណបានទិន្នា ៗ
ខ្ញុះស្រឡាញ់អ្នកលេងបេះប្រៀងឥត

តែភ្លឺឡើងតាំងរៀបមារីស្វា
ប្រោះទឹកអប់ជុំត្រឡប់តាំងកាយា
បបួលកៀនយាត្រាទាំងរាត្រី ។
ចូលទៅស្ដាប់ចិត្តមិនបាប់ទំនុកប្រៀន
អង្គុយមៀងមើលប្រុសដែលបេត្តី
ប្របៀតក្រោយលួចឲ្យស្វាមារី
ប្រុសមានទីនាំលីណាចូលស្ពក ។
លលើទៅឥតខ្វាសស្ដាសរឆ្ងើង
ដូចដំរីចុះប្រេងគ្រៃលេងភ្លុក
ហ្នូខ្វាន់(១)កាប់សាប់សិរបំបែមុខ
មិនពរុកចាក់ពងពងចូលពេង ។
ញាតិសន្តានរោសំតៀនឲ្យទឹងហ្នូ

---

១ ហ្នូ គឺទមក; ខ្វាន់ គឺមង្គល, សួស្ដី ។ បានសេចក្ដីថា ។
មង្គល ។

ត្រឡប់ខឹងតបតតែប្អូន

ជេរគេឯងថាកូនជាស្រីពេន

គ្នាដៃព្រោនតែខ្លួនថាខ្លួនជា ។

គោតហ្នួនពោលក្បួនសុភាសិត

មិនប្រព្រឹត្តតាមពង្សវង្សមេបា

ទៅស្រឡាញ់អ្នកលេងតែងកាយា

នាំផឹកស្រាជក់អាភៀនញៀនអស់ប្រាណ ។

ខ្លះស្រឡាញ់ប្តីគេ ។ មានប្រាក់

លួចលាក់ស្ម័គ្រស្មោះចិត្តមិនគិតស្មាន

ប្រពន្ធគេ ។ ដឹងខឹងរំខាន

ខ្លួនទៅបានក៏បានជាចុងគេ ។

មែនប្រទះប្រពន្ធដើមធ្ងើមប្រច័ណ្ឌ

ខឹងក្តួចកាន់បង្កាយាជបញ្ចោរជេរ

ខ្លួនជាចុងប្រុងចុះនៅក្រោមគេ

សុខគ្មានទោមេអើយកុំសង្ស័យ ។

ខំផ្គាប់គេយកចិត្តស្បីតគេគាប់

គុណត្រឡប់ទៅជាទោសទាំងយប់ថ្ងៃ

កោតចិត្តកម្លាពេញចៅក្រ

យកប្ដីគេខុសនិស្ស័យបានក្ដីក្ដៅ ។

ស្ដាយអើយស្ដាយរូបកងស្រស់ពិសី

មិនគប្បីយកប្ដីឲ្យហ្មងសៅ

ញាតិសន្ដានបងប្អូនស្ដីប្រដៅ

មិនតាមវង្សពង្សផៅទើបសៅហ្មង ។

យកប្ដីគេឲ្យគេជេរបកមុខ

កំឡោះគេពេញស្រុកម្ដេចមិនបង

គេចំនេរតាមតែចិត្តខ្លួនល្អង

នឹងបែរខ្នងប្ដីបែរមុខតាមសុខចិត្ត ។

នេះកម្មអើយទៅបានឯប្ដីគេ

ឲ្យគេជេរជៀលប្រាណគ្មានអាណិត
ព្រោះខ្លួនខាងឆោតល្ងៅខ្លៅមិនគិត
ទៅជឿចិត្តប្រុសប្រឡោមលោមឲ្យលង់ ។
ស្រីតួកនេះគ្មានបំរើនទេឆោតខ្លៅ
ស្រីណាឆៅឆោតទៅក៏អស់ទ្រង់
ឯនារីទើបតែពេញចំទង់
កុំគ្រាប់យកទុកអង្គឲ្យអប្រិយ ។
សុភាសិតយើងតែងទុកទូន្មាន
ខំរើសយកទុកប្រាណផោបញ្ចប់ស្រី
ទាញយកត្លួស្រីជួមកស្រដី
ផាទីតៀនស្នាតើស្រីពល់គ្នា ។
មានស្រីខ្វះក្តាហានមិនមានគ្រឿង
គប់ប្រុសពីគោរមអំពើចិត្តពាលា
រផឹងណោះពុំងណោះមិនបេះក

ប្រុសដឹងគ្នាកើតសម្លាប់កាប់គ្នាឯង ។
ទាល់លុះទូវព្រះរាជអាជ្ញាហ្លួង
ត្រូវគេខួងជួងកប្រវ៉ាក់វែង
ឲ្យឡើងលើឈើអណ្ដាតគេដោតខ្លួន
បីថ្ងៃតែងស្លៀកសំណាញ់សៀតផ្កាប្យា ។
ដើរអាក្រាសព្វសុសទៅតាំងស្រុក
ស្រមូញមុខកើតទុក្ខអនេកណា
សែនខ្មាសសល់តាល់តួតួរអនិច្ចា
ព្រោះប្រាជ្ញាប្រុសពីរសុំមិនឈប់ ។
មានស្រីខ្លះលុះល្បែងលេងបៀរប៉ោ
ប្រុសបោមឆោលេងភ្នាល់ទាល់ព្រលប់
ចាញ់អស់ប្រាក់គ្មានចាក់ក៏ពុំឈប់
ដល់ពេលយប់យកទ្រព្យលក់ឲ្យចិន ។
មួយដំឡឹងពីរដំឡឹងក៏ព្រមស្ម័គ្រ

ឲ្យតែខានបានប្រាក់តាក់ប៉ៅស៊ិន
ខ្លួនមិនមានសេរីសុខជាយួនបិន
សំដែងក្បិនចុះក្បួនអ្នកស៊ីន ៗ
៦ ។ អនិច្ចានារីរូបស្រស់ល្ហាវ
កំពុងសាវទើតពកកពន្ធកល្អ
មិនគេក្សត់យោឲ្យមឹងហ៊ា
ទឹងបានតវង្សវែងអង្វែងទៅ ៗ
នេះបង្ខំកាច់លក់កំពុងពក
ចុះថ្ងៃថោកក៏យកឲ្យគេស្រូវ
កោតហ៊ាគេម្តេចគេដើរខុសផ្លូវ
ត្រូវទៅពាល់លុះចុះកេងវែង
ទឹងពឹងញាតិគេក៏ស្អប់មិនរាប់អាន
ព្រោះសន្តានគិតខុសលុះដោយល្បែង
គេបានហាមខ្លួនមិនតាមត្រឡប់ក្លែង

ថាគេព្យាបាទឯងមិនឲ្យបាន ៗ
ដល់ញាក់ខ្លួនខ្លួនក្លាយជាខ្ញុំគេ
ទឹងបែបរេរកញាតិជួយប្រោសប្រាណ
ញាតិឯណាទីមួយនឹងជួយបាន
សុំបុត្រសានឡើងជារៀលបីរយបាទ ៗ
មុខក្រជាំខំបំរើការប្រាក់គេ
ខ្ជិលគេជេរវាយទៅតាមមារយាទ
ទោសតាំងនេះព្រោះចៅមិនតាមញាតិ
គិតប្រមាទល្បែងក្តរល់ដល់វេទនា ៗ
ប្រុសអ្នកល្អគាលណោះនឹងក្លាហាន
មករូមស្នានយកចៅជាភរិយា
បានតែពួកអ្នកលេងល្បែងដូចគ្នា
នោះទើបវាយកចៅទៅតាមកម្ម ៗ
មានស្រីខ្លះធ្លាសភ្លៀវកៀវចង់ប្រុស

ដែលមានយសខ្ពស់ស័ក្តិដ៏មួនមាំ
ស្វែងរៀនស្នេហ៍ខ្សែគល់ដាក់ប្រចាំ
សាំចាំងថ្នាំយ៉ាបឿ (១) បានដូចប៉ង ។
ប្រុសក៏លង់វង្វែងស្រឡាញ់ខ្លាំង
រាក៏តាំងតែងខ្លួនឲ្យនួនល្អង
បង្អាប់ប្រុសឲ្យលុះក្នុងបំណង
ចាំចិត្តបង់បុះអំណាចខ្លាចរាខ្លប ។
រាក៏លួចលាក់ប្រាក់ចាយតាមចិត្ត
លេងបាំងផ្ចិតចល់មុខគ្នាហាប
ជួនប្រាំជងម្តង ៗ ផ្ទេរពីជប
ចាល់តែក្របធ្លាក់ក្រត្រដរទៅ ។
ខ្សែសង្ហារបារ៉ុកទ្រុមគងអង្គ
ក៏លួចយកទៅបញ្ចុំគ្នាសល់នៅ

---

១ យ៉ាបឿ = ថ្នាំបំពុល (ពាក្យថៃ) ។

លេងគ្រឿងយសទាល់តែអស់ពីខូទៅ
ប្ដីមិននៅក៏ចាយជាតិឲ្យគេ ។
ប្ដីត្រឡប់ដឹងសព្វជាអស់ធន
ទោះជាខឹងខឹងប្រពន្ធមិនហ៊ានជេរ
ក្រែងវាលែងឯងខានមិនបានស្នេហ៍
ក៏ខំតែបាំងបិទយកបត្ដវា ។
បងប្អូនដឹងគេក៏ខឹងទៅប្រាយប្រាប់
ទៅប្ដីនោះមិនជឿស្ដាប់ពាក្យគេថា
ត្រឡប់ខឹងនឹងពួកញាតិកា
ទាល់តែធ្លាក់សក្ដានិច្ចខ្លួន ។
៨ / អាណិតមនុស្សប្រុសមកលុះលង់
ឲ្យមាតុគ្រាមគ្របអង្គមិនគង់ក្បួន
អស់សម្បត្តិមាសប្រាក់ធ្លាក់ទាំងខ្លួន
វាមានប្រុសដល់បីប្អូនក៏បិទទៅ ។

កើតទាំងនេះក៏ព្រោះក្មេងកគេពេល

មិនកញ្ឈ្រោលផោលពេញសម្ងំទៅ

ទាល់តែឲ្យវាពេលលោកក្ដៅ

ក៏ស៊ូទៅតាមកម្មចាំចិត្តស្នេហ៍

ទាំងវាសោកពេះតែសាងសំអាងអគ្គ

ឲ្យប្រុសលង់ក្នុងកាមតាមតែបែរ

គប់សហាយប្ដីដឹងក៏ប្រឹងតែក

ស៊ូស្បថស្បែឲ្យប្ដីចុះជឿចិត្ត ។

ស្លាបារីផ្គាប់ប្ដីពេញប្រអប់

ប្ដីក៏សព្វគាប់ចិត្តរឹងស្នាលស្និទ្ធ

ស្មានប្រពន្ធស្ម័គ្រស្មោះអស់ពីចិត្ត

តែងដឹកវាងដុលដល់សហាយ ។

ផ្គង់ទាំងពីរមិនឲ្យប្រុសសន្ទិះ

ផ្គាប់ឯណោះផ្គង់ឯនេះបានសប្បាយ

មាយានេះប្រុសមិនដឹងគុណថ្លៃបាខាយ
តាំងចិត្តហ្មាយថាប្រពន្ធខ្លួនស្លូតត្រង់ ។
ទោះគេប្រាប់ក៏មិនស្ដាប់មិនជឿស្ដែង
ព្រោះឃើញវាផ្គាប់ឯងនោះពេញវង្ស
មិនសង្កេតមើលហេតុទៅខាងក្នុង
ឃើញតែក្រៅហើយក៏ស្ងុងជឿថាជា ។
ប្រុសល្ងង់ល្ងឹតដោយពុទ្ធិពាលពេលខ្លាំង
មោហៈបាំងមើលមិនយល់កលមាយា
ឱ! អនិច្ចាជាតិប្រុសនេះខុសគ្នា
ម្ដេចក៏គ្មានបញ្ញារំពឹងខ្លះ ។
ខ្លះនោះសោតឆោតឆៅខ្លៅខ្លាចស្រី
វាប្រើជ្រប់គេសើស្មើគញ្ជះ
បើទៅគេសុំមកពុំបានខ្លះ
តែជប់ផ្ទះវាក៏ដះដូចក្ដើនព្រៃ ។

កាលគេបានគ្រាន់ក្សាន្តអររីក
បើមិនបាននោះកុំនឹកឡើយអ្នកម៉ែ
បាយនឹងស៊ីឃើញជាមិនឆ្អែតផ្អៃ
យប់នោះដេកទៃទេហើយតាជី ៗ
ឃើញតែបានត្រង់បង់មិនបង់បង់
តែមិនយកចិត្តចង់ជួយស្វាមី
ការគិតតួបកំដួបប្រើតែប្ដី
ហោបទៅដល់ស្វាបារីប្ដីម្បរឯង ៗ
ស្រូវអង្ករដាក់ទុកជង្រុកធំ
កើបដូរនំដូរមីស៊ីជាល្បែង
តាយកធំស៊ីក៏ធំមិនមានក្រែង
តែប្ដីខ្វើតវ៉ាកីខ្វង់ចំផែងស្លោះ ៗ
មួយបើតាល់គិតគលកុហកប្ដី
បិទសេចក្ដីអាក្រក់ទុកក្នុងពោះ

LIBRARY
BUDDHIST INSTITUTE

ប្ដីដឹងដល់ផ្កាល់នេះរាំផ្ញញ់នោះ
ប្ដីជាពេ្ញះរាំជាពេ្ញះមិនបេះបើម ៗ
មានស្រីខ្លះមាក់ងាយព្រោះប្ដីខ្សត់
គិនសត្តត់ឲ្យលុះអំណាចព្រម
ប្រើប្ដូកពារលើកស័ក្តិមាក់ទៅបម
តែប្ដីឈមរាំកំប្រែកមិនប្រែប ៗ
ញាតិសន្តានខានប្ដីមិនរាប់អាន
តែសន្តានខានខ្លួនបេះប្រកប
ញាតិណាមានរាប់អានទៅអរគប
ញាតិណាក្រុបក្រែប្រាក់មាក់រាំហី ៗ
មានស្រីខ្លះមាក់ងាយព្រោះប្ដីខ្លៅ
បង្គាប់ទៅតាមការមិនផ្គត់
ប្រើទៅគោះស្ដីតិះបេបគ្រប់ប្ដី
ផ្ដើម ៗ ទោះជាត្រូវក៏នៅខុស ៗ

បានបន្តិចប៉ុចអួតបញ្ញាឯង

ជាចេះបាត់ចេះដែងដើមព្រានខ្ពស់

កន្ធិបាហ៊ក្អកយើងប្រុស ។

ទៀយស៊ូរតែបិទរស់ឈ្មោះមិនបាន ។

មានស្រីខ្ទុះមាក់ឆាយព្រោះប្ដីតាប

អួតអត្តភាពមានពង្សវង្សសន្តាន

និយាយអ៊ូទឹងប្ដីពុំទុនព្រាណ

ប្ដីហើយបានតែមួយម៉ាត់កាត់យកឯង ។

គ្មានគោរពប្រតិបត្តិបរើប្ដី

បើធ្វើអ្វីឲ្យតែដៃបង្អុលខ្វែង

តាំងចំពួយដៃចំតាស់បង់បំផែង

ស្ដីកំហែងតែងគំហកបន្គ្រឹមប្ដី ។

ប្ដីពុំហ៊ានហើយហាថាអ្វីឲ្យ

បេះតែឃោយឲ្យប្រើធ្វើអ្វី ។

តាស់បន្ទិចហក់ក៏ក្ដិចប្ដីឯមន្ត្រី
អាងតែប្ដីឥតញាតិជាអ្នកធំ ។
ញាតិខាងគេ ៗ ក៏កាន់ហក់កំង
ឯងមិនខុសហក់ខឹងរឹងបង្ខំ
គោងទន់តាមទើបបានគ្រាន់សម្ញុំ
តែឯងខំហក់ខែងឯងក៏ខូច ។
ប្រពន្ធធំលើសប្ដីអប្រិយពិត
៩ ។ អាណិតទៅប្ដីគ្មានពង្សពូជ
រឺឯណាក៏បានព្រោះប្រាណតូច
គោងទទួលខុសខូចលើអាត្មា ។
ខែអនង្គនារីរូបចំណាប់
អញ្ជើញស្ដាប់ស្រីខូចណា៎នួនណា៎
ស្រីពួកនេះសឹងចុះក្នុងតម្រា
ត្រកូលកាឡកណ្ណីស្រីសាមាន្យ ។

នាងកុំត្រាប់តាមគេណា៎មេទូច
នឹងអាប់អង្គពង្សពូជវង្សសន្តាន
ឧស្សាហ៍តាំងសតិលើកប្រាណ
បើឯងបានស្វាមីគប្បីផង ។
បំរុងផ្គាប់ដោយកាយវាចាចិត្ត
សុចរិតចិត្តស្មោះកក្តីត្រង់
ចូរស្ងួនស្ងៀមបៀមគ្លួ(១)បន្ទន់អង្គ
កុំប្រកួតកាន់វង្សឲ្យកើនណា៎ ។
ពេលនិទ្រាចូរបោសទីដំណេក
កាលនឹងដេកៗថ្ងួននៃកស្តា
កុំទន្ទឹមគៀតកើយខ្នើយស្មើគ្នា
ចូរនិទ្រាខិតក្រោមល្មមប្រតិបត្តិ ។
ដល់ពេលក្រោកចូរនាងក្រោកមកមុនប្តី

---

១ បៀមគ្លួ = ប្រុងខ្លួន (ពាក្យថៃ) ។

ស្លាបារីទឹកទន់នាងរៀបចាត់
ពេលល្មមដាស់ ៗ ប្ដីដោយកិច្ចវត្ត
គឺលើកហត្ថស្ដាំចាប់បាទព្រះភស្ដា ។
ប្ដីចេញមកយកទឹកទន់លុបភក្ត្រ
កន្សែងសាក់ហុចឲ្យជូតភក្ត្រា
ចេញមកចាត់ដាំស្លតាមវេលា
ស្រេចកាលណាលើកមកតាំងតាមទី ។
អញ្ជើញប្ដីបរិភោគគ្រឿងក្រយា
លាងដៃស្វាមីឲ្យអស់ពាគី[១]
អង្គុយនៅបំរើប្រចាំទី
ប្ដីហូបរួចសូមស៊ីជាក្រោយហោង ។
បើប្ដីហៅបួលថាសអធ្យាស្រ័យ
នាងលើកដៃសំពះជាឧបដង

១ ពាគី = គ្រឿងមន្ទិល ។

អង្គុយបត់បាតាណានួនល្អង
ជាចំនង់គោរពនូវភស្តា ។
សួរបេបាយខ្វល់ខ្វាយក្នុងការខ្លួន
មើលថែជួនសព្វទីស្រែចំការ
ខាងការស្រីភ្នាក់ងារនៃកញ្ញា
ទិវសព្វហ៍កុំប្រមាទឲ្យខាតខាន ។
ប្ដីទៅព្រៃនាងស្រីរក្សាផ្ទះ
មើលដំរះបោសច្រាសលំនៅស្ថាន
ប្ដីរកស៊ីបានមកឲ្យកល្យាណ
រក្សាទុកកុំមានក្ដីមាក់ងាយ ។
អព្យាស្រ័យពួកញាតិសាលោហិត
យកជាមិត្រប្រួទុកសុខសប្បាយ
បានអ្វីម្ហូបគប្បីនាងចែកចាយ
មើលនាយអាយឲ្យគួរទីសន្តាន ។

កុំធ្វើងៃឆ្មកាន់ខ្លួនខ្ពស់វិលក្ខណ៍
ឲ្យកើនស័ក្តិកើនយសហួសវង្សកើន
ប្រើមធ្យមឲ្យសមទឹងសន្តាន
កេក្រព្រាណរៀនប្រុបស្របកស្តា ។
ប្រការមួយរៀនស្តីឲ្យគួរស្តាប់
បញ្ចេញស័ព្ទឲ្យសមទឹងវាចា
បើប្តីថ្នាក់នាងជួយយកចិត្តា
ប្រឡោមស្វាមីមិនឲ្យមានទោះ ។
មែនប្តីភ្លើងឯងទឹកលត់ឲ្យភ្លុត
កុំកហេតុឲ្យកើតជាជំលោះ
ទោះប្តីខឹងនាងប្រឹងអត់ទុនចុះ
យកតិពោះតតបឲ្យគាប់កល ។
ទឹងនិយាយតាយតាត់ប្រយ័ត្នមាត់
កុំនិយាយប្រើនបទនាំរវល់

ភ្លើងខាងក្រៅកុំគាវចូលមណ្ឌល
ភ្លើងខាងក្នុងប្រុងដំកល់កុំនាំចេញ ៗ
ការឯណាអប្រិយដែលប្ដីហាម
ប្រព្រឹត្តតាមបែបផែនឲ្យមែនមិញ
កុំកេងកាងអាងដ្បិតប្ដីស្រឡាញ់
គិតកកាញ់ការមិនគាប់ទឹងធ្លាប់ទៅ ៗ
ទោះពុំកេធក្រោធខឹងទឹងកស្ដា
កុំនិន្ទាស្ដីដើមយល់មិនត្រូវ
ប្រឹងលេបទុកកត់ទុកក្នុងកាយបៅ
ទុកស្រាហ៍បិទបាំងទៅកុំប្រែប្រាយ ៗ
មែនបើទាស់កើតមោះឈ្មោះប្រកែក
កុំកូកស្រែកចេញស័ព្ទឲ្យឮឆ្ងាយ
មើលបើប្ដីមាត់ខ្លាំងជាងសូសោយ
ប្ដូរចៀសចេញឲ្យឆ្ងាយពីនោះទៅ ៗ

ទំពាំកក្រពុនចិត្តប្តីសូមទៀនមក
មើលលៃលកយកចិត្តភស្តាចៅ
ឃើញស្ងប់ស្ងាត់បាត់បានសូមតាមផ្ទៅ
និយាយទៅឲ្យឃើញហេតុនោះហោង ។
ក្មើនកំពុងដេះខ្វាំងកុំតាំងដុត
យកផ្លូនចេញឲ្យផុតកុំគរគង
គង់លេតផុតផ្លូនទេ្យនន្លង
បើបិត្តគងនាងកុំក្ដឹះកះផ្ញាញ់ផ្ញាល់ ។
ឈ្មោះប្រកែកបែកចិត្តឥតប្រយោជន៍
កើតអសោចកើតអសារការគ្មានផល
ហេតុនោះនួនបួស្រេនកុំខ្វាយខ្វល់,
គេក្រាកើតតាមគលឲ្យកើតសក្តិ ។
ឋមបិតទៅកុំបើកពិចិត្តបី
បូរគ្គីសុចរិតស្វាមីភក្តិ

ដូចយ៉ាងនាងសីតាប្រកបល័ក្ខណ៍
ទសក័ក្រមិនអាចទំងជិតបាន ។
សុចរិតចិត្តល្អទឹងកើតផល
ជាកុសលចំរើនសុខក្សេមក្សាន្ត
ទេពធិតឲ្យពរបរិបូណ៌បាន
ក្ដីក្នុងស្ថានមនុស្សលោកយោគសង្កិនាយ ។
កិត្តិគុណកិត្តិយសស័ព្ទសុសសព្វ
ក្ងនត្រឡប់សព្វទិសពិរោះសាយ
តពូជពង្សវង្សវែងអង្វែងឆ្ងាយ
ជនទាំងឡាយសឹងសរសើរទួនអនន្ត ។
ការប្រព្រឹត្តិស្លូតត្រង់ត្រូវចិត្តប្តី
ប្តីគេរបេត្តិកបកិសៈវង់
ទោះរូបនាងអាក្រក់ពិការសង្គ
តែចិត្តត្រង់ប្តីក៏ត្រេកដេកមិនឆ្ងាយ

មែនរូបល្អតែចិត្តចោរអប្រិយ
ដូចកាកីកែកែបរូបឆើតឆាយ
ចោរបើកចោលព្រហ្មទត្តក្សត្រពណ្ណរាយ
ទៅសហាយនឹងគ្រុឌរត់ចោលប្ដី ។
បានសុបណ្ណមិនឆ្អន់មិនឆ្អែតឈប់
ទៅសម្តពគន្ធ័ន[1] ទៀតជាបី
ត្រូវបណ្ដែតពោងពាយក្នុងជលធី
សូន្យជីវិតក្នុងទឹកនឹកអនិច្ចា ។
នេះព្រោះចិត្តរាយមាយមិនសន្ដោស
បានទុក្ខទោសបុះត្រូវព្រះអាជ្ញា
រឿងនិទានក៏មានក្នុងសាស្ត្រា
នាងឧស្សាហ៍មើលទុកជាច្បាប់ស្រី ។
ច្បាប់ស្រីហ្វឹងអង្គដួងទ្រង់តែងទុក

១ គន្ធព្វៈ «អ្នករាំ» សៀមអានថា គន្ធន ។

មានទំនុកពិស្ដារតាមបាលី

ប្ដូរគេយកមកមើលណា នាងស្រី

ជាគ្រឿងតឿនស្មារតីបានក្ដីគាប់ ។

សុភាសិតយើងនេះតែងសរឆ្ងើប

ព្រោះមានបែបបុរាណក៏ច្រើនច្បាប់

ខឹងតែងសាំក៏សាំក៏នតម្រាប់

អញ្ជើញស្ដាប់តែសរឆ្ងើបជាបែបថ្មី ។

ខ្ញុំសូមទោសអ្នកស្រីដែលប្ដីលែង

ទឹងស្រីល្បែងប្រព្រឹត្តក្បត់ចិត្តប្ដី

បើបានព្ទប៉ូរអំណត់កាន់ខន្តី

កុំស្រដីនិន្ទាខ្ញុំអ្នកតែង ។

បន្តិចថាអៈតាក្យការប្រាជ្ញព្រោក

លើកប្រយោគជាទៅតែឯង ។

បានតម្រាពីណាមកសំដែង

តែងឡើងតែងឲ្យយើងនេះខ្វាបប្ដី ៗ
ខាងប្រុសតើម្ដេចមិនតែងមិនបែងចាត់
ឲ្យប្រតិបត្តិប្រពន្ធខ្លះកើតប្អី
នេះអាងគាត់ ៗ ប្រុសបេះស្រដី
បង្គាប់ស្រីឲ្យតែស្រីតាមជាងប្រុស ៗ
ខាងប្រុសគេមានស្រីពីរបីបាន
ប្រាប់គ្នានហាមប្រាមថាមានទោស
ត្រង់យើងស្រីលេងខ្លះផ្កាសថាខុស
អាងតែប្រុសប៉ះតែងមកកែងថា ៗ
លេងបៀរប៉ោអស់ប្រាក់ ៗ យើងមាន
ទៅសូមទានពីគាត់មកកាលណា
រវល់អ៊ូមកហាមយើងគ្រប់គ្នា
បើគាត់ជាក៏ជាតែគាត់ទៅ ៗ

បើស្រីណា ដៀលត្មះឲ្យស្រីនោះ
ធ្លាក់ទៅចុះក្នុងស្ថាននរកជ្រៅ
យមបាលអុជអាលដោយដែកក្ដៅ
មានផ្សង់បុះមាត់ព័ទ្ធពេញប្រាណ ៗ
ក្លិនកំស្អុយធ្អាបផ្អះអសោចិ៍ឆ្ងាយ
ពិការកាយកើតស្លាប់រាប់ពុំបាន
អស់កំណត់មកកើតជាប្រេតប្រាណ
ជាតិវេទនាដ៏ទុក្ខឥតសុខា ៗ
កើតជាមនុស្សមាត់ស្អុយអ្នកផងស្អប់
គ្មានគេគប់ចង់យកជាភរិយា
កើតវិបត្តិខ្វាត់ខ្វាយព្រាត់ប្រាសគ្នា
ហ្វូងទេវតាសាឲ្យវិបរិត ៗ
បើស្រីណាគបកេរ្តិ៍ភរិយា គាប់
បានត្រង់ត្រាប់ស្ដាប់យកទុកក្នុងចិត្ត

ប្រតិបត្តិធ្វើតាមសុភាសិត
ទេពមានឫទ្ធិបួលជួយបំរើនជ័យ ។
ឲ្យស្រីនោះបរិបូណ៌សុខក្សេមក្សាន្ត
ស្លាប់ទៅបានកើតក្នុងសួគ៌ាល័យ
ដោយសម្បត្តិឥតទុក្ខឥតកាភ័យ
សម្រាន្តញ្ញវិមានជាទិព្វារ ។
ទេពអប្សរអរទុនមកស្ងនស្ងើ
ហោមជុំស្នើបំរើជាបរិវារ
សូត្រថ្វាយជ័យឲ្យស័ព្ទសាធុការ
ជាអស្ចារ្យឮសព្ទទាំងរាត្រី ។
ដោយសុខសួគ៌អស់ផលបុះមកកើត
យកកំណើតជាមនុស្សក្នុងលោកីយ
កើតក្នុងវង្សព្រះបរមចក្រី
គបកសីល្បីកេរ្តិ៍សព្វទិសា

ទ្រង់ព្រះរូបឆើតឆោមជាចមស្រី
លើសនារីក្នុងស្ថានយើងនេះណា
ជាឯកអគ្គមហេសីនៃចក្រា
សែនសុខាត្រាដល់ទិព្វាននាយ ។
នៃអនង្គនារីនាងបូស្ដាប់
ប្រុងត្រងត្រាប់យកទុកក្នុងអង្គកាយ
ប្រតិបត្តិឲ្យត្រូវដូចបរិយាយ
ទឹងសំរេចដូចហ្នាយនេះជៀងជាក់

មួយសូមទោសពួកប្រុសកំឡោះក្មេង
បណ្ដាលេងបង់ស្រីតាមក្ដីស្ម័គ្រ
ក្រែងស្រីណាបង់តឹងបិនបានអ្នក
អ្នកកុំអាក់អន់ចិត្តដល់ខ្ញុំឯង ។
ថាពីដើមបង់អោយសប្បាយចិត្ត
ដល់មានសុភាសិតកាព្យពៃង

ប្រតិបត្តិធ្វើតាមសុភាសិត
ទេពមានឫទ្ធិចូលជួយចំរើនជ័យ ។
ឲ្យស្រីនោះបរិបូណ៌សុខក្សេមក្សាន្ត
ស្លាប់ទៅបានកើតក្នុងសួគ៌ាល័យ
សោយសម្បត្តិឥតទុក្ខឥតភ័យ
សម្រាន្តក្នុងវិមានជាទេព្ធារ ។
ទេពអប្សរទេវមកស្នងស្នើ
ហោមជុំស្នើបំរើជាបរិវារ
សូត្រថ្វាយជ័យឲ្យស័ព្ទសាធុការ
ជាអស្ចារ្យឮសព្វទាំងរាត្រី ។
សោយសុខសួគ៌អស់ផលចុះមកកើត
យកកំណើតជាមនុស្សក្នុងលោកីយ
កើតក្នុងវង្សព្រះបរមចក្រី
កបកសីល្ប៍កេរ្តិ៍សព្វទិសា

ទ្រង់ព្រះរូបឆើតឆោមជាចមស្រី
លើសនារីក្នុងស្ថានយើងនេះណា
ជាឯកអគ្គមហេសីនៃបក្រា
សែនសុខាត្រាដល់ទិញ្ញនាយ ។
នៃអនគ្គនារីនាងបូស្តាប់
ប្រុងត្រងត្រាប់យកទុកក្នុងអង្គកាយ
ប្រតិបត្តិឲ្យត្រូវដូចបរិយាយ
ទឹងសំរេចដូចហ្វាយនេះជៀងជាក់

    មួយសូមគោសព្វកប្រុសកំឡោះក្មេង
បណ្តាលេងបង់ស្រីតាមក្តីស្ម័គ្រ
ក្រែងស្រីណាបង់តឹងមិនបានអ្នក
អ្នកកុំអាក់អនចិត្តដល់ខ្ញុំឯង ។
ថាពីដើមបង់ផាយសប្បាយចិត្ត
ដល់មានសុភាសិតកាព្យពៃង

ពួកស្រី ៗ រាបេះមិនលុះល្បែង
ព្រោះអាចារ្យឥន្ទតែងបានជាតឹង ៗ
កុំគិតក្រែងថាខ្ញុំឈ្នានីសអ្នក
មិនឲ្យបានរួមរ័កនឹងស្រីហ្នឹង
តែគឺមោះស្រីនោះគេល្អជឹង
បានជារឹងគេមិនតាមចិត្តអ្នក ៗ
វិស័យស្រីល្អកបឥរិយា
ចាំមាតាបិតាគេទុកដាក់
រូបអ្នកឯងប្រាថ្នាលេងលួចលាក់
តែបានស្ម័គ្រឆ្អែតហើយក្រែងឆ្អើមវិញ ៗ
ហេតុនោះបានជាមិនបង់គប់
ប្រែត្រឡប់ជាស្អប់មិនស្រឡាញ់(១)

---

១ ត្រង់ចុងឃ្លានេះ កប់ជួន, បើថា «ប្រែត្រឡប់ជាស្អប់កើតទុក្ខម្នេញ» ទើបជាប់ជួនតាមច្បាប់កាព្យ ។

ចាំម៉ែផុគេដាក់គេដាំវិញ
ទោះខឹងចេញទោះខឹងចោលបង្គោលមាន ៗ
ដូចអ្នកឯងស្វែងរកប្រពន្ធល្អ
ប្រាថ្នាតពូជពង្សវង្សសន្តាន
បើស្រីនោះរូបល្អម្ហូបគ្មាន
អ្នកមិនហ៊ានទទឹងចូលទៅសម្ពន្ធ ៗ
ការលេងស្រីនេះមិនងាយទេណាអ្នក
ស្រីអប្បល័ក្ខណ៍នោះមានគ្រប់ដំបន់
លេងឯណោះលេងឯណេះមិនចេះស្រន់
អ្នកឯងមុនគេក្រោយដោយពេញស្រុក ៗ
ស្រីចង់ងាយបានងាយលែងក៏ងាយ
អ្នកកុំហ្មាយថាបានសេចក្តីសុខ
ស្រីសាមាឲ្យយើងបានសំដែងទុក
មានទាងមុខមកហើយចូរមើលចុះ ៗ

មួយពាសីខ្ញុំគេអ្នកទៅតាមស្ត្រ
រាគោងអ្នក ៗ ឯងក៏តេះតុះ
ត្រូវគេចាប់សែនខ្លាចក៏ខ្លួបឈ្មោះ
កេរ្ដិ៍ឮសុសខ្លាសគេសុត្រទិសា ៗ
ជូនប្រុះស្រីឈ្ងួលបបួលលេង
បានមួយភ្លេងពីរភ្លេងក៏ភ្លាត់ថា
ដេកសន្ទឹងតមថ្នាំត្រាំសុរា
ចុះអទិច្ចាបង់ប្រាក់ទិញថ្នាំជៀប ៗ
ស្រីក៏ខូចប្រុសក៏ខិលមានច្រើនយ៉ាង
ទឹងអែបអាងពាញយកមកតែងប្រៀប
លើសកម្លាំងទឹងលើកសរសេរជៀប
យើងពយរៀបតែល្អមចូលចិត្តបាន ៗ

លោកណាបានអានមើលសុភាសិត
មិនគាប់ចិត្តក៏ចៀសចេញកុំអាន

បើលោកណា គាប់ចិត្តតាមសណ្ដាន

អញ្ជើញអានប្រយ័ត្នរូបក្រាំង(១)ខ្ញុំ ។

កុំឲ្យខ្ជាយទឹកមាត់ជិតប្រឡាក់

កុំឲ្យធ្លាក់ពីដៃក្រាំងទក់គ្រាំ

ក្រដាសដាចដាច់ផ្ទត់ចេញពីពុម្ព

កាណិតខ្ញុំបំណាច់ខ្ញុំតែងតាំង ។

បរិយាយច្រើន ៗ កើនកំណត់

ខ្ជិលពេយមាត់កាយហាត់អស់កំឡាំង

ពេលក៏ជួនបញ្ចប់ចុះឯវិ

និដ្ឋិតចប់ស្មេះប៉ុណ្ណេះហោង ។

---

១ កាលដែលឧកញ៉ាសុត្តន្តប្រីជា ឥន្ទ តែងសុភាសិតនេះ បាន សរសេរចុះក្នុងក្រាំងជាដំបូង ។

# បញ្ជីសៀវភៅ

## ដែលពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយ

| | | | |
|---|---|---|---|
| កច្ចាយនូបត្ថម្ភកៈ | ភាគទី ១ | ១សៀវភៅថ្លៃ | ២២,០០ |
| " | " ២ | — | ២៦,០០ |
| កាលាមសូត្រ និងបរាភវសូត្រ | | — | ២០,០០ |
| កុម្ភជាតក | | — | ៣,០០ |
| ក្បួនរាជសព្ទ | | — | ០,០០ |
| ក្រុងសុភមិត្រ | ភាគទី ១ | — | ៥,០០ |
| " | " ២ | — | ៤,០០ |
| " | " ៣ | — | ៣,០០ |
| ខេមាខេមសរណកថា | | — | ០,០០ |
| គតិលោក | ភាគទី ១ | — | ៤,០០ |
| " | " ២ | — | ៤,០០ |
| " | " ៣ | — | ៤,០០ |
| " | " ៤ | — | ៤,០០ |
| " | " ៥ | — | ៤,០០ |
| " | " ៦ | — | ៤,០០ |

| | | |
|---|---|---|
| គតិលោក ភាគទី ៧ | ១ សៀវភៅ ថ្លៃ | ៤,០០ |
| ″ ″ ៨ | — | ៤.០០ |
| ″ ″ ៩ | — | ៤,០០ |
| ″ ″ ១០ | — | ៤,០០ |
| គម្ពីរវិធីសារ | — | ១០,៥០ |
| គិរិមានន្ទសូត្រ | — | ៣,០០ |
| គិហិប្រតិបត្តិពិស្ដារ | — | ១០,០០ |
| គិហិប្រតិបត្តិសង្ខេប | — | ០,០០ |
| គោលសមថកម្មដ្ឋាន | — | ៦,០០ |
| គំរូច្បាប់ជាក់ខ្មែរ | — | ១២,០០ |
| ឃរាវាសធម៌ | — | ០.០០ |
| ចំរៀងជាតិនិយម ភាគទី ១ | — | ៨,០០ |
| ចំរៀងសន្តិភាព ភាសាបារាំង | — | ១៥.០០ |
| ច្បាប់ល្បើកថ្មី | — | ៨,០០ |
| ច្បាប់ត្រីនេតិ | — | ០,០០ |
| ច្បាប់ក្រម | — | ០,០០ |
| ច្បាប់កូនចៅ | — | ០,០០ |
| ច្បាប់ផ្សេង ៗ ភាគទី ១ | — | ៤,០០ |
| ″ ″ ២ | — | ០.០០ |

| | | |
|---|---|---|
| ច្បាប់ភជនីតិ | ១ សៀវភៅ ថ្លៃ | ០,០០ |
| ច្បាប់កេរ្តិ៍កាលថ្មី | — | ០,០០ |
| ច្បាប់កេរ្តិ៍កាលចាស់ | — | ០,០០ |
| ជយវរ្ម័នទី ៧ | — | ៥,០០ |
| ជយវរ្ម័ន ទី ៧ ភាសាបារាំង | — | ១០,០០ |
| ញាណកថា | — | ២,០០ |
| ដើមកំណើតអង្គរ | — | ៤,៥០ |
| ដើមកំណើតអង្គរ ភាសាបារាំង | — | ២០,០០ |
| ដំណាលពុទ្ធចេតិយ | — | ០,០០ |
| គេបិយជាតក | ១០ សន្លឹក | ៩,០០ |
| ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៤៩ | ១២ សៀវភៅ ថ្លៃ | ៩៦,០០ |
| 〃 〃 ៥០ | — | ១៤៥,០០ |
| 〃 〃 ៥១ | — | ១៤៥,០០ |
| 〃 〃 ៥២ | — | ១៨៣,០០ |
| 〃 〃 ៥៣ | — | ១៩២,០០ |
| 〃 〃 ៥៤ | — | ២០០,០០ |
| 〃 〃 ៥៥ | — | ២១០,០០ |
| 〃 〃 ៥៦ | — | ២៣០,០០ |
| 〃 〃 ៥៧ | — | ២៣០,០០ |

| | | |
|---|---|---|
| ទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ ១៩៥៨ | ១២ សៀវភៅ ថ្លៃ | ២៣០,០០ |
| 〃 ៥៩ . . | — | ២៣០,០០ |
| ទសបារមីកថា . . . . . | ១ សៀវភៅ ថ្លៃ | ៦,០០ |
| ទសធម្មសូត្រ . . . . . | — | ០,០០ |
| ទានកថា . . . . . | — | ៦,០០ |
| ទឹកទន្លេសាប . . . . . | — | ០,០០ |
| ទំនៀមការផ្លាស់ខ្លួន . . . . | — | ៧,០០ |
| ធម្មប្រទីប . . . . . | — | ១០,០០ |
| នាគោបមាទិកថា . . . . | — | ១,៥០ |
| នានាជាតក . . . . . | — | ១២,០០ |
| បករណវិសេសោ . . . . | — | ០,០០ |
| បក្ខគណនាវិធីនិងបក្ខសម្រេច . . . | — | 〃 |
| បញ្ចអភិណ្ហបច្ចវេក្ខណ . . . | — | ៣,០០ |
| បញ្ញាសជាតក បាលី ភាគទី ១ . . | — | ១៦,០០ |
| 〃 〃 ២ . . | — | ១២,០០ |
| 〃 〃 ៣ . . | — | ១២,០០ |
| 〃 〃 ៤ . . | — | ១២,០០ |

| | | | |
|---|---|---|---|
| បញ្ញាសជាតកសម្រាយ ភាគ ទី ១ | | ១ សៀវភៅ ថ្លៃ | ២៤,០០ |
| 〃 〃 ២ | | — | ១៥,០០ |
| 〃 〃 ៣ | | — | ១៥,០០ |
| 〃 〃 ៤ | | — | ១៥,០០ |
| បទានុក្រមភាមកើ្ត | | — | ២,០០ |
| បញ្ញាប្ពូកសង្ខេប | | — | ៨,៥០ |
| បភាវសូត្រ | | — | ០,០០ |
| បដិហេតុសង្ខេប | | — | ៨,០០ |
| បាយាសិរាជញ្ញសូត្រ | | — | ២,៥០ |
| បិសាចស្នេហា | | — | ០,០០ |
| បុណ្ណោវាទសូត្រ | | — | ០,០០ |
| បេសនិយបត្ត | | ១សន្លឹក | ១,០០ |
| បែបសកវាទិ | ឆ្នាំ ១៩៣១ | ១ សៀវភៅ ថ្លៃ | ០,៤៥ |
| | ១៩៣២ | — | ០,៤៥ |
| | ១៩៣៣ | — | ០,៤៥ |
| បែបអក្សរខ្មែរ | | — | ០,០០ |
| ប្រជុំរឿងព្រេងខ្មែរ ភាគទី១ | | — | ២០,០០ |
| 〃 ២ | | — | ២២,០០ |
| ប្រវត្តិព្រះមហាពោធិព្រឹក្ស | | — | ២,០០ |

| | | |
|---|---|---|
| ប្រស្នាវិន័យបិដកសង្ខេប . . . | ១ សៀវភៅ ថ្លៃ | ២៩,០០ |
| ពន្លឺអាស៊ីទិព . . . . . | — | ២៤,០០ |
| ពាក្យកាព្យប្រដៅជនប្រុសស្រី . . . | — | ៣,០០ |
| ពាក្យកាព្យច្រៀងរឿងពុទ្ធប្បវត្តិ . . . | — | ៣,០០ |
| ពិធីទ្វាទសមាស ភាគទី ១ . . . | — | ១៥,០០ |
| " " ២ . . . | — | ១៧,៥០ |
| ពិធីទ្វាទសមាស ភាសាបារាំង . . . | — | ៣០,០០ |
| ពុទ្ធមាមកវិធី . . . . . | — | ៨,០០ |
| ពុទ្ធប្បវត្តិតាមចំនួនបិនភាសាបារាំង . . | — | ១០,០០ |
| ពុទ្ធោវាទានុសាសនី . . . . | — | ៤,០០ |
| ព្រហ្មចរិយកថា . . . . . | — | ១៥.០០ |
| ព្រះបាទអសោក . . . . . | — | ១៦,០០ |
| ព្រះបង្គមកែវ . . . . . | — | ៧,០០ |
| ព្រះត្រៃលក្ខណ៍និងសំវេគកថា . . . | — | ៤,០០ |
| ភាណវារបាលី . . . . . | — | ៣៧,០០ |
| មគ្គុទេសនគរ ភាគទី ១ . . . . | — | ៨,០០ |
| " " ២ . . . . | — | ២០.០០ |
| មនោបុព្វកថា . . . . . | — | ៣,០០ |
| មរណានុស្សតិកម្មដ្ឋាន . . . . | — | ៣,០០ |

| | | |
|---|---|---|
| មហាជនកជាតក | ១០ សៀវភៅ ថ្លៃ | ៥.០០ |
| មហាវេស្សន្តរជាតក | ១ — | ៤៣.០០ |
| មហាបុរិសលក្ខណៈ | — | ៣.០០ |
| មាតាបិតុបដ្ឋានកថា | — | ៦.០០ |
| មិត្រល្អ | — | ០·០០ |
| មិលិន្ទបញ្ហា ភាគទី ១ | — | ២០,០០ |
| " " ២ | — | ១៨,០០ |
| មួយរយគាថា | — | ០,០០ |
| រតនប្បភា | — | ៧,០០ |
| របាំខ្មែរ ភាសាបារាំង | — | ៧០,០០ |
| រាមកេរ្តិ៍ពីខ្សែ ១ ដល់ ១០ | — | ៤,០០ |
| " ៧៥ - ៨០ | — | ២,០០ |
| រឿងកាកី | — | ៧,០០ |
| ល្បើកទូន្មានកូនចៅបិន | — | ៣,០០ |
| លោកនយបករណ៍ភាគ ទី ១ | — | ២២,០០ |
| " " ២ | — | ២៣,០០ |
| លក្ខន្តិកវត្ត | — | ៨,០០ |
| លោកានុសាសនី | — | ០,០០ |

| | | |
|---|---|---|
| វចនានុក្រមខ្មែរ ភាគ ទី ១ . . . | ១ សៀវភៅ ថ្លៃ | ១០៥,០០ |
| " " ២ . . . | — | ១៣៦,០០ |
| វិសាលសូត្រ . . . . . | — | ៣,០០ |
| វិជ្ជាបរណកថា និងគិរិមានន្ទសូត្រ . . | — | ៦,០០ |
| វិជ្ជាប្រាំបីប្រការ . . . . . | — | ១៤,៥០ |
| វិធីបង្ការរោគ . . . . . | — | ១,០០ |
| វិសុទ្ធិមគ្គ បាលី ភាគទី ១ . . . | — | ៥១,០០ |
| " " ២ . . . | — | ៥០,០០ |
| " " ៣ . . . | — | ៥០,០០ |
| វុឌ្ឍោទ័យ . . . . . | — | ០,០០ |
| វេយ្យាករណ៍សំស្ក្រឹត . . . . | — | ២៨,០០ |
| សត្តបរិត្តទ្វាទសបរិត្ត . . . . | — | ១៧,០០ |
| សតិប្បដ្ឋានសូត្រ . . . . | — | ៨,៥០ |
| សប្បុរិសធម៌ . . . . . | — | ៤,៥០ |
| សម្ពន្ធមាលា . . . . . | — | ៤០,០០ |
| សាមណេរវិន័យ. . . . . | — | ៧,០០ |
| សារទេសនា . . . . . | — | ២,០០ |
| សិលាចារឹកនគរវត្ត . . . . | — | ១៥,០០ |
| សីមាវិនិច្ឆ័យ . . . . . | — | ៣,០០ |

| | | |
|---|---|---|
| សីលនិទ្ទេស | ១ សៀវភៅ ថ្លៃ | ១៦,០០ |
| សិង្គាលោវាទសូត្រ | — | ៦,០០ |
| សុភាសិតប្បកាសិនី | — | ៦,០០ |
| សុភាសិតច្បាប់ស្រី | — | ៥,០០ |
| សុភូតិសូត្រ | — | ១,៥០ |
| សុរាទោសកថា | — | ១,៥០ |
| សុរិយយាត្រឡើងស័ក | — | ៣,០០ |
| សៀវភៅយានជំនិះខ្មែរ | — | ០.០០ |
| សេកសោមបណ្ឌិត | — | ៣.០០ |
| សេចក្ដីរំលឹកដាស់តឿន | — | ៣.០០ |
| សំដែងអំពីព្រះនិព្វាន | — | ១.០០ |
| សំដែងនិយធម៌ | — | ២.០០ |
| អក្ខទោសកថា | — | ០,០០ |
| អក្សរខ្មែរធៀបនឹងរូបសត្វ | — | ០,០០ |
| អក្សរខ្មែរជាប់នឹងរូបរាមកេរ្តិ៍ | — | ០,០០ |
| អត្ថានុសាសនី | — | ៦,០០ |
| អនត្តលក្ខណសូត្រ | — | ២.០០ |
| អនុមោទនាវិធី | — | ៧,០០ |

| | | |
|---|---|---|
| អនុត្តរិយសូត្រ . . . . . | ១ សៀវភៅ ថ្លៃ | ១,០០ |
| អភិនវភាសិត . . . . . . | — | ៣,០០ |
| អភិធម្មត្ថសង្គហៈ សម្រាយ . . . . | — | ២៥,០០ |
| " បាលី . . . . . | — | ០,០០ |
| អរិយសច្ចកថា . . . . . . | — | ១០,០០ |
| អវសានកិច្ច . . . . . . | — | ១០.០០ |
| អាឡវកសូត្រ . . . . . . | — | ៥,០០ |
| ឯកសហស្សរាត្រី ភាគទី ១ . . . . | — | ៥,០០ |
| " " ២ . . . . | — | ៤,០០ |
| " " ៣ . . . . | — | ៤,០០ |
| " " ៤ . . . . | — | ៤,០០ |
| " " ៥ . . . . | — | ៤,៥០ |
| " " ៦ . . . . | — | ៣,០០ |
| " " ៧ . . . . | — | ៥.០០ |
| " " ៨ . . . . | — | ៥,០០ |
| " " ៩ . . . . | — | ៤.០០ |
| " " ១០ . . . . | — | ២,០០ |
| " " ១១ . . . . | — | ២,០០ |
| " " ១២ . . . . | — | ២.០០ |

| | | | |
|---|---|---|---|
| ឯកសហស្រភាគី | ភាគ ទី ១៣ | ១សៀវភៅ ថ្លៃ | ៥.០ |
| " | " ១៤ | — | ៧.០ |
| " | " ១៥ | — | ១០,០ |
| " | " ១៦ | — | ៦,៥ |
| " | " ១៧ | — | ៥,៥ |
| " | " ១៨ | — | ៥,០ |
| " | " ១៩ | — | ៧,០ |
| " | " ២០ | — | ៨,០ |
| " | " ២១ | — | ៨,០ |
| " | " ២២ | — | ៨.០ |
| " | " ២៣ | — | ៨.០ |
| " | " ២៤ | — | ៨,០ |
| " | " ២៥ | — | ៦,០ |
| " | " ២៦ | — | ៧.០ |
| " | " ២៧ | — | ៧,០ |
| " | " ២៨ | — | ៨,០ |
| " | " ២៩ | — | ៧.០ |
| " | " ៣០ | — | ៧.០ |
| " | " ៣១ | — | ៨,០ |

| | | |
|---|---|---|
| ឯកសហស្រវគ្រី ភាគទី ៣២ . . . | ១ សៀវភៅ ថ្លៃ | ៨,០០ |
| " " ៣៣ . . . . | — | ៨.០០ |
| " " ៣៤ . . . . | — | ៨ ០០ |
| " " ៣៥ . . . . | — | ៨,០០ |
| " " ៣៦ . . . . | — | ៨,០០ |
| " " ៣៧ : . . . | — | ៨,០០ |
| " " ៣៨ . . . . | — | ៨,០០ |
| " " ៣៩ . . . . | — | ៦,០០ |
| " " ៤០ . . . . | — | ៦,០០ |
| " " ៤១ . . . . | — | ៦,០០ |
| " " ៤២ . . . . | — | ៦,០០ |
| " " ៤៣ . . . . | — | |
| " " ៤៤ . . . . | — | |
| ឧភិទបាតិមោក្ខ . . . . . . | — | ២១,០០ |
| អំពីប្រាសាទខ្វះនៅអង្គរ. . . . . | — | ១៣,០០ |
| អំពីព្រះពុទ្ធសាសនា . . . : . | — | ៥១,០០ |